ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤

ឆ្នាំ២០២៣ ជាឆ្នាំពិសេសរបស់ព្រឹទ្ធសភា ក្រោមព្រឹត្តិការណ៍សំខាន់ជាប្រវត្តិសាស្ត្រ ២គឺ៖

១-នីតិកាលទី៤ ព្រឹទ្ធសភាឈានមកដល់ទីបញ្ចប់ នាដើមឆ្នាំ២០២៤

២-នីតិកាលទី៥ ព្រឹទ្ធសភា ត្រូវចាប់ផ្តើមចាប់តាំងពីត្រីមាសទី២ ឆ្នាំ២០២៤។

ក្រោមសម្ពាធនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាត្រូវម្ចាស់ការ ដើម្បីគិតគូរចាត់ចែងរៀបចំការងារសព្វសារពើ និងគ្រប់វិស័យឱ្យបានរលូន និងល្អប្រសើរសម្រាប់ពេលខាងមុខនេះ។

ឆ្នាំ២០២៣ ជាឆ្នាំនៃការតស៊ូរៀបចំ និងត្រៀមបត់បែនតាមលក្ខខណ្ឌតម្រូវការថ្មីក្នុងបរិបទថ្មីក្នុងក្របខ័ណ្ឌជាតិ តំបន់ និងពិភពលោក។

ព្រឹទ្ធសភាទំនើប បៃតង និងឌីជីថល នៅជាទិសដៅយុទ្ធសាស្ត្រឆ្ពោះទៅឆ្នាំ២០៣០ដដែល។

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារនីតិកម្ម**

-បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន ២០លើក ប្រជុំពេញអង្គ ចំនួន ១០លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន ០២លើក ដែលមានរបៀបវារៈដូចខាងក្រោម៖

១-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន ២៣ច្បាប់

២-ស្តាប់របាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៩ និងលើកទី១០, លើកទី១០ និងលើកទី១១ នីតិកាលទី៤

៣-ពិនិត្យ និងអនុម័តលើសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

៤-ពិនិត្យសម្រេចលើរបាយការណ៍ទូទាត់ថវិកា ឆ្នាំ២០២២ និងការបែងចែកឥណទាន ឆ្នាំ២០២៣

-បានរៀបចំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការជំនាញ និងប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ ចំនួន ២៣ច្បាប់



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oumsarith_sgsenate@gmail.com, oumsarith_sgsenate@yahoo.com

-បានរៀបចំប្រជុំគណៈកម្មការកែសម្រួលបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

-បានរៀបចំកិច្ចប្រជុំជូនសមាជិកព្រឹទ្ធសភាជួបពិភាក្សាជាមួយក្រុមការងារបច្ចេកទេសរៀបចំសេចក្តីព្រាងច្បាប់របស់ក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌ ចំនួន ០២លើក។

**២- មុខងារតាមដានការអនុវត្តច្បាប់**

**-បានរៀបចំចាត់ចែង និងផ្តល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា៖**

- អញ្ជើញជួបសវនាការការងារជាមួយគណៈប្រតិភូក្រសួង ស្ថាប័ននានា ចំនួន ១៩លើក រួមមាន៖ ក្រសួងព័ត៌មាន, រាជបណ្ឌិត្យសភាកម្ពុជា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, អគ្គនាយក-អន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ, ប្រធានមន្ទីរអប់រំ យុវជន និងកីឡា, ប្រធានមន្ទីរធម្មការ និងសាសនា, ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ និងប្រធានមន្ទីរទេសចរណ៍ ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ, អាជ្ញាធរមានសមត្ថកិច្ច ប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀល ខេត្តស្ទឹងត្រែង, ប៉ុស្តិ៍នគរបាលប្រចាំការនៅច្រកទ្វារកំពង់ផែអន្តរជាតិភ្នំពេញ និងអាជ្ញាធរប្រចាំការនៅច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដើម្បីឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ ការគ្រប់គ្រងជនអន្តោប្រវេសន៍, វឌ្ឍនភាពការងារ បញ្ហាប្រឈម និងទិសដៅអនុវត្តបន្ត
- អញ្ជើញចុះបេសកកម្ម ចំនួន ១៩លើក ដើម្បីសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់ ការផ្សព្វ-ផ្សាយច្បាប់ ការអនុវត្តគោលនយោបាយនានា, ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការបម្រើសេវាសាធារណជូនប្រជាពលរដ្ឋ, ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការគ្រប់គ្រងថែទាំកុមារ, ការគ្រប់គ្រងកិច្ចអភិរក្ស និងការអភិវឌ្ឍវិស័យទេសចរណ៍, ការងារមូលនិធិ, បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ នៅខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្ត-បាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី
- អញ្ជើញចុះបំពេញទស្សនកិច្ច និងសិក្សាឈ្វេងយល់អំពីសក្តានុពលក្នុងវិស័យកសិកម្ម និងវិស័យទេសចរណ៍ ចំនួន ០៣លើក នៅខេត្តព្រះវិហារ ខេត្តកំពង់ស្ពឺ និងតំបន់អភិវឌ្ឍន៍ឧកញ៉ាម៉ុង កែវផុស។

## ៣-មុខងារតំណាង

**-បានរៀបចំចាត់ចែង និងផ្តល់សេវាជូន៖**

- សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា, ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អនុប្រធានទី១ព្រឹទ្ធសភា និងឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភាបាន៖
  - អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកសម័យប្រជុំដំបូងរដ្ឋសភា និងពិធីសច្ចាប្រណិធាន សមាជិក សមាជិកា នៃរដ្ឋសភា និងរាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៧
  - អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន និងអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធសមិទ្ធផល កិច្ចប្រជុំ វេទិកា សិក្ខាសាលា ពិធីសាសនា ព្រមទាំងចូលរួមពិធីផ្លូវការផ្សេងៗ នៅរាជធានី-ភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន ១៣៤លើក
- សមាជិក សមាជិកាព្រឹទ្ធសភាបាន៖
  - រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារអនុវត្តមុខងារតំណាងឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣
  - រៀបចំវេទិកាជាមួយក្រុមប្រឹក្សាសង្កាត់ ចំនួន ០២លើក ស្តីពី ការអភិវឌ្ឍមូលដ្ឋាន និងបម្រើប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ធានាបានសុខសន្តិភាព នៅទូទាំង១២ខណ្ឌ ក្នុងរាជធានីភ្នំពេញ
  - រៀបចំកិច្ចប្រជុំជាមួយសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន នៅវិមានព្រឹទ្ធសភា មានអ្នកចូលរួម ចំនួន ១៣៨នាក់
- ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ មន្ត្រីរាជការ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ, ការងារសន្តិសុខ សណ្តាប់ធ្នាប់, ការផ្តល់សេវាសាធារណៈជូនប្រជា-ពលរដ្ឋ, ការអនុវត្តគោលនយោបាយនានា, ការកសាង និងពិនិត្យហេដ្ឋារចនាសម្ព័ន្ធ, សម្ពោធសមិទ្ធផលនានា, នាំយកអំណោយ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅតាមបណ្តាខេត្ត ក្រុងនានា ចំនួន ១,៤៦៦លើក ព្រមទាំងអញ្ជើញជាគណៈអធិបតីក្នុងកិច្ចប្រជុំ សិក្ខាសាលា វេទិកា ពិធីសាសនា និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន ១,២០៨លើក
- សមាជិកព្រឹទ្ធសភា ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រុមការងាររបស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចុះពិនិត្យ និងព្យាបាលជំងឺប្រគេនព្រះសង្ឃ និងជូនប្រជាពលរដ្ឋក្រីក្រ ចំនួន ២៨លើក នៅ

រាជធានីភ្នំពេញ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តតាកែវ ខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ ខេត្តកែប និងតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ

-បានរៀបចំពិធីបំពាក់គ្រឿងឥស្សរិយយសជូនសមាជិក សមាជិកាព្រឹទ្ធសភា ចុងនីតិកាលទី២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា

-ឯកឧត្តម អ៊ុំ សារិទ្ធ អគ្គលេខាធិការព្រឹទ្ធសភា និងឯកឧត្តម ឡោក ឆាយ អគ្គលេខាធិការរងព្រឹទ្ធសភា បានចុះធ្វើការងារសង្គមកិច្ចជួយប្រជាពលរដ្ឋក្រីក្រ នៅសង្កាត់ទាំង៥ ក្នុងខណ្ឌជ្រោយចង្វារ ចំនួន ០៦លើក

-បានរៀបចំជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមជាអធិបតីក្នុងកិច្ចប្រជុំពិភាក្សាការងារ សិក្ខាសាលា បាឋកថា កិច្ចជំនួប ទស្សនកិច្ច និងកម្មវិធីផ្សេងៗសរុបចំនួន ៣៨លើក

-បានទទួលដំណើរទស្សនកិច្ច និងធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងដំណើរការនីតិកម្មរបស់ព្រឹទ្ធសភា ប្រគេនព្រះសង្ឃ និងជូនមន្ត្រីរាជការ សាស្ត្រាចារ្យ សិស្ស និស្សិតនៃសាកល-វិទ្យាល័យ សាលារៀន និងសិក្ខាកាមនៃវគ្គបណ្តុះបណ្តាលនានា ព្រមទាំងគណៈប្រតិភូនារាជប៉ុន ចំនួន ៨៩៩អង្គ/នាក់

-បានតុបតែងលម្អសង្ក្រាន្ត និងរៀបចំពិធីសូត្រមន្ត ព្រមទាំងពិធីទទួល និងអបអរសាទរទេវតាឆ្នាំថ្មី ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ នៅវិមានព្រឹទ្ធសភា

-បាននាំយកសម្ភារ និងថវិកាមួយចំនួនរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា

-បានឧបត្ថម្ភថវិកាជូនក្រុមគ្រូពេទ្យមកប្រចាំការក្នុងម៉ោងរដ្ឋបាល ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ចំនួន ៤,០០០,០០០រៀល

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅនៅបណ្ណាល័យព្រឹទ្ធសភា ចំនួន ៤៨០នាក់

-បានផ្តល់សៀវភៅដែលបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រគេនព្រះតេជគុណគង់នៅវត្តសំពៅមាស និងជូនសាលាខេត្តបន្ទាយមានជ័យ សាកលវិទ្យាល័យ សាលារៀននានា សរុបចំនួន ៦៦៤ក្បាល ព្រមទាំងបានផ្តល់សៀវភៅទិនានុលេខន៍ជូនមជ្ឈមណ្ឌលឯកសារកងយុទ្ធពលខេមរភូមិន្ទភូមិភាគទី៥ ខេត្តបាត់ដំបង ចំនួន ១៧ក្បាល

-បានផលិត និងផ្សព្វផ្សាយទស្សនាវដ្តីប្រចាំខែមករា ដល់ខែធ្នូ ឆ្នាំ២០២៣ ចំនួន ៩,៦០០ក្បាល

-បានរៀបចំផលិតខ្សែវីដេអូសមិទ្ធផលរបស់ព្រឹទ្ធសភា ចំនួន ០៩ខ្សែ ស្តីពី៖

- វឌ្ឍនភាពការងាររយៈពេល១ឆ្នាំ ក្នុងឆ្នាំទី៥ នៃព្រឹទ្ធសភា នីតិកាលទី៤
- ការអភិវឌ្ឍរយៈពេល១ឆ្នាំ ក្នុងឆ្នាំទី៦ ព្រឹទ្ធសភា នីតិកាលទី៤
- លទ្ធផលការងារក្នុងរយៈពេល១ឆ្នាំ ក្នុងមុខងារតំណាងរបស់ព្រឹទ្ធសភា ប្រចាំឆ្នាំ២០២២
- លទ្ធផលការងារក្នុងរយៈពេល១ឆ្នាំ ក្នុងមុខងារតំណាងរបស់ព្រឹទ្ធសភា ប្រចាំឆ្នាំ២០២៣
- សមិទ្ធផលការងាររបស់គណៈកម្មការទី៥ព្រឹទ្ធសភា ប្រចាំនីតិកាលទី៤ (ឆ្នាំ២០១៨-២០២៤)
- សមិទ្ធផលការងាររបស់គណៈកម្មការទី៨ព្រឹទ្ធសភា ប្រចាំនីតិកាលទី៤ (ឆ្នាំ២០១៨-២០២៤)
- សមិទ្ធផលការងាររបស់ក្រុមសមាជិកាព្រឹទ្ធសភា ប្រចាំនីតិកាលទី៤ (ឆ្នាំ២០១៨-២០២៤)
- សកម្មភាពក្រុមសមាជិកាព្រឹទ្ធសភា ឆ្នាំ២០២៣
- ព្រឹទ្ធសភា នីតិកាលទី៤ (ឆ្នាំ២០១៨-២០២៤)

-បានធ្វើបច្ចុប្បន្នភាព រៀបចំផលិត និងផ្សព្វផ្សាយ៖

- សៀវភៅបត់ស្តីពី ព្រឹទ្ធសភា នីតិកាលទី៤ (ភាសាខ្មែរ និងអង់គ្លេស) ចំនួន ២,០០០ក្បាល
- សៀវភៅបត់ស្តីពី តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការទាំង១០ព្រឹទ្ធសភា ចំនួន ១,០០០ក្បាល
- សៀវភៅទិនានុលេខន៍ព្រឹទ្ធសភា ឆ្នាំ២០២៤ ចំនួន ២,៨០០ក្បាល
- ប្រតិទិនព្រឹទ្ធសភា ឆ្នាំ២០២៤ ចំនួន ២,៥០០ក្បាល
- ប្រតិទិនផែនការកម្មវិធីការងារប្រចាំថ្ងៃ ប្រចាំឆ្នាំ២០២៤ ចំនួន ៨០០ច្បាប់
- សីមីសម្គាល់អត្តសញ្ញាណព្រឹទ្ធសភា ចំនួន ១,០០០សន្លឹក
- ប័ណ្ណរថយន្តចេញ-ចូល ក្នុងបរិវេណព្រឹទ្ធសភា ឆ្នាំ២០២៤ ចំនួន ៣,៥២៥សន្លឹក

-បានរៀបចំចាត់ចែងបញ្ជូនសារលិខិតថ្វាយព្រះពរ លិខិតជូនពរ លិខិតថ្លែងអំណរគុណ លិខិតអបអរសាទរ របស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទូលថ្វាយព្រះ-ករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា, សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ និងគោរពជូនសម្តេចអគ្គ-មហាសេនាបតីតេជោ ហ៊ុន សែន ប្រធានឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា, សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឥស្សរជនជាន់ខ្ពស់តាមក្រសួង ស្ថាប័ននានា ក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សា, ចម្រើនជន្មាយុ, ពិធីខួបកំណើត, ពិធីទទួលគោរមងារ, ពិធីទទួលគ្រឿងឥស្សរិយយស, ពិធីបុណ្យប្រពៃណីជាតិ និងអន្តរជាតិផ្សេងៗសរុបចំនួន ១០៨លិខិត

-បានចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខក្នុងនាមថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៤២លិខិត ជូនរាជវង្សានុវង្ស និងគ្រួសារឥស្សរជន ថ្នាក់ដឹកនាំតាមក្រសួងស្ថាប័ននានា ព្រមទាំងរៀបចំជូនគណៈប្រតិភូព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមក្នុងពិធីគោរពវិញ្ញាណក្ខន្ធ ពិធីបញ្ចុះសព និងពិធីបូជាសព ចំនួន ២៣លើក

-បានទទួលពាក្យបណ្តឹង ចំនួន ៣៧បណ្តឹង ធ្វើកំណត់បង្ហាញពាក្យបណ្តឹង ចំនួន ២៩បណ្តឹង ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីពិនិត្យដោះស្រាយ ចំនួន ២៩បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន ០៨បណ្តឹង ឆ្លើយតបទៅម្ចាស់បណ្តឹង ចំនួន ៣១បណ្តឹង ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ចំនួន ១២បណ្តឹង តម្កល់ទុកមិនចាត់ការ ចំនួន ០៨បណ្តឹង ធ្វើលិខិតរម្លឹកជំរុញការដោះស្រាយពាក្យបណ្តឹង ចំនួន ០២បណ្តឹង ដោះស្រាយបញ្ចប់ ចំនួន ០២បណ្តឹង និងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ដើម្បីជូនជ្រាប ចំនួន ១២បណ្តឹង។

**៤-មុខងារសហប្រតិបត្តិការអន្តរជាតិ**

-បានរៀបចំចាត់ចែង និងផ្តល់សេវាជូនសម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា ក្នុងពិធីជូនសារតាំង ជំនួបសវនាការ សម្តែងការគួរសម និងពិភាក្សាការងារជាមួយគណៈប្រតិភូជាតិ-អន្តរជាតិ ឥស្សរជនជាន់ខ្ពស់ និងអគ្គទូតនានា ចំនួន ២១លើក រួមមាន៖ ប្រធានាធិបតី នៃសាធារណរដ្ឋសហព័ន្ធ-អាល្លឺម៉ង់, នាយករដ្ឋមន្ត្រី នៃប្រទេសម៉ាឡេស៊ី, នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រថៃឡង់ដ៍, ប្រធានរដ្ឋ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ, ប្រធានរដ្ឋសភា នៃសាធារណរដ្ឋកូរ៉េ, ប្រធានរដ្ឋសភា នៃសាធារណរដ្ឋសហព័ន្ធប្រជាធិបតេយ្យនេប៉ាល់, អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន, អនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍សភាប្រឹក្សានយោបាយប្រជាជនចិន, សមាជិកព្រឹទ្ធសភានៃប្រទេសកាណាដា, ឯកអគ្គរដ្ឋទូត នៃប្រទេសអូស្ត្រាលី សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋឥណ្ឌូនេស៊ី, ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រជប៉ុន ព្រះរាជាណាចក្រថៃឡង់ដ៍, ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព ទើបតែងតាំងថ្មី នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត សាធារណរដ្ឋអ៊ុយក្រែន សាធារណរដ្ឋអាស៊ែបៃហ្សង់, ឯកអគ្គរាជទូតទើបតែងតាំងថ្មី នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំបណ្តាប្រទេសជាមិត្ត ចំនួន ១៥រូប, ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល (Global Life Sharing) នៃសាធារណរដ្ឋកូរ៉េ, គណៈប្រតិភូនារីកម្ពុជា ចំនួន ២០០នាក់ ដឹកនាំដោយលោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រីក្រសួងកិច្ចការនារី

-បានរៀបចំចាត់ចែង និងផ្តល់សេវាជូន ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា អនុប្រធានទី១ព្រឹទ្ធសភា ក្នុងជំនួបពិភាក្សាការងារទ្វេភាគីជាមួយលោកជំទាវ សិន យេយេ អនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍សភាប្រឹក្សានយោបាយប្រជាជនចិន នៃសាធារណរដ្ឋប្រជាមានិតចិន ព្រមទាំងពិធីលៀង

សាយកោជនផ្លូវការជូនដាក់ត្តិយសដល់លោកជំទាវ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ

-បានរៀបចំចាត់ចែង និងផ្តល់សេវាជូនឯក**ឧត្តមកិត្តិសង្គហបណ្ឌិត ទេព ង៉ន** អនុប្រធានទី២ព្រឹទ្ធសភា៖

- អញ្ជើញអមព្រះរាជដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម **សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងទៅបំពេញព្រះរាជទស្សនកិច្ចផ្លូវរដ្ឋ នៅសាធារណរដ្ឋឥណ្ឌា
- អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ទៅបំពេញទស្សនកិច្ចការងារ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ព្រមទាំងចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៤ (AIPA-44) នៅសាធារណរដ្ឋឥណ្ឌូនេស៊ី

-បានរៀបចំ សម្របសម្រួលបែបបទ ផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិ មហាសន្និបាត វេទិកា សិក្ខាសាលា និងទស្សនកិច្ចការងារនៅក្រៅប្រទេស ចំនួន ២៥លើក នៅសាធារណរដ្ឋបារាំង សាធារណរដ្ឋតួកគី ប្រទេសហ្សកហ្ស៊ី ប្រទេសអង់ហ្គោឡា ប្រទេសស្វីស ប្រទេសកាណាដា ព្រះរាជាណាចក្រម៉ារ៉ុក ព្រះរាជាណាចក្របារ៉ែន សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋឥណ្ឌា ប្រទេសម៉ុងហ្គោលី សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-បានរៀបចំចាត់ចែង និងផ្តល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងពិធីជំនួបសវនាការសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ អង្គទូត និងអ្នកវិនិយោគគិននានា ចំនួន ២០លើក

-ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បាន៖

- អញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិ និងបំពេញទស្សនកិច្ចនៅក្រៅប្រទេស ចំនួន ០៥លើក នៅព្រះរាជាណាចក្របារ៉ែន ព្រះរាជាណាចក្របែលហ្ស៊ិក ប្រទេសអង់ហ្គោឡា សាធារណរដ្ឋកូរ៉េ និងសាធារណរដ្ឋសង្គមនិយមវៀតណាម
- អញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខារវាងវិទ្យាស្ថានសភាអាស៊ី (PCAsia) និងលេខាធិការដ្ឋាន (AIPA)
- អនុញ្ញាតឱ្យភ្ញៀវជាតិ-អន្តរជាតិ និស្សិតអាហារូបករណ៍ និងដៃគូអភិវឌ្ឍនានា ចូលជួបសម្តែងការគួរសម ពិភាក្សាការងារ និងទទួលអនុសាសន៍ ចំនួន ១៦លើក

-ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយលោក Wang Ke ប្រធានមូលនិធិ PEACELAND នៅវិមានព្រឹទ្ធសភា

-ឯកឧត្តម **លឹម ប៊ុនហុក** អតីតអគ្គលេខាធិការរងព្រឹទ្ធសភា បានៈ

- ដឹកនាំគណៈប្រតិភូសភាកម្ពុជា អញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមអ្នកនយោបាយនៃអន្តរសភាអាស៊ាន លើកទី១៤ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម
- អមដំណើរគណៈប្រតិភូព្រឹទ្ធសភាចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៤ (AIPA-44) នៅសាធារណរដ្ឋឥណ្ឌូនេស៊ី

-គណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញចូលរួមសិក្ខាសាលានៅក្រៅប្រទេស ចំនួន ០២លើក នៅព្រះរាជាណាចក្របែលហ្ស៊ិក និងព្រះរាជាណាចក្រថៃឡង់ដ៍

-បានសហការរៀបចំទទួល-ជូនដំណើរ និងបដិសណ្ឋារកិច្ចគណៈប្រតិភូអន្តរជាតិ អញ្ជើញមកទស្សនកិច្ចនៅព្រឹទ្ធសភាកម្ពុជា ចំនួន ០៨លើក រួមមានៈ គណៈប្រតិភូនៃសភាប្រឹក្សានយោបាយប្រជាជនចិន, គណៈប្រតិភូសមាជិកព្រឹទ្ធសភាតំណាងឱ្យប្រជាជនបារាំងនៅបរទេស និងជាសមាជិកក្រុមមិត្តភាពព្រឹទ្ធសភាបារាំង-កម្ពុជា, គណៈប្រតិភូមេឃុំ **WOIPPY** នៃសាធារណរដ្ឋបារាំង, គណៈប្រតិភូខេត្តតៃនិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម, គណៈប្រតិភូនៃប្រទេសស៊ុយអែត ដើម្បីកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍អន្តរជាតិ Sida និងគណៈប្រតិភូមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ

-បានសហការជាមួយវិទ្យុមិត្តភាពកម្ពុជា-ចិន និងសមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន រៀបចំពិធីតាំងពិព័រណ៍សមិទ្ធផលខួប១០ឆ្នាំ នៃការរួមគ្នាកសាងខ្សែក្រវ៉ាត់ និងផ្លូវ រវាងកម្ពុជា-ចិន និងកិច្ចសំណេះសំណាលជាមួយប្រិយមិត្ត អបអរសាទរខួបគម្រប់១៥ឆ្នាំនៃការបង្កើតវិទ្យុមិត្តភាពកម្ពុជា-ចិន នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា

-បានរៀបចំពិធីប្រគល់-ទទួលអំណោយដែលជាជំនួយរបស់បណ្តាប្រទេសជាមិត្ត ចំនួន ០៣លើក រួមមានៈ

- រថយន្ត ពីសាធារណរដ្ឋប្រជាមានិតចិន តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន ០៥គ្រឿង និងពីសាធារណរដ្ឋកូរ៉េ តាមរយៈអង្គការបក្សីខៀវ ចំនួន ០១គ្រឿង
- សម្ភារបណ្ណាល័យអេឡិចត្រូនិច និងសម្ភារសិក្សាអេឡិចត្រូនិច ពីស្ថានទូតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា
- សម្ភារការិយាល័យ ពីរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតសិង្ហបុរី, ស្ថានទូតចិន, ស្ថានទូតម៉ាឡេស៊ី, ស្ថានទូតព្រុយណេ, ស្ថានទូតឥណ្ឌា, ស្ថានទូតថៃ, ស្ថានទូតវៀតណាម, ស្ថានកុងស៊ុលសេដ្ឋកិច្ច និងពាណិជ្ជកម្ម, ទីស្តីការគណៈរដ្ឋមន្ត្រី, អង្គការមូលនិធិអាស៊ី, អង្គការតម្លាភាពកម្ពុជា (TI Cambodia), មូលនិធិចិន

ដើម្បីសន្តិភាព និងការអភិវឌ្ឍ, មូលនិធិចិនដើម្បីអភិវឌ្ឍន៍ជនបទ, មូលនិធិ Peace Land, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC), សាកលវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៃទីក្រុងហាណូយ (USTH), សាកលវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៃទីក្រុងហាណូយ (RMIT), សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, សាកលវិទ្យាល័យអាស៊ី-អឺរ៉ុប, សាកលវិទ្យាល័យលីមកុកវីង, មជ្ឈមណ្ឌលសភាអាស៊ី(PCAsia), បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា(CADT), សាលារៀន CAM-ASEAN, វិទ្យាស្ថានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, វិទ្យាស្ថាន Proseth, វិទ្យាស្ថាន Sunrise, វិទ្យាស្ថាន SalaCyber, វិទ្យាស្ថានជាតិស្ថិតិ (NIS), វិទ្យាស្ថានជាតិសង្គមកិច្ច, ភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ព្រះរាជាណាចក្រថៃឡង់ដ៍(TICA), សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន, សមាគមសាលាត្រាជូ, សមាគមនារាយុវជនអាស៊ីអាគ្នេយ៍, វិទ្យុមិត្តភាពកម្ពុជា-ចិន, ក្រុមហ៊ុន KOHA, ក្រុមហ៊ុន HUAWEI, ក្រុមហ៊ុន CODEDONE និងក្រសួង ស្ថាប័ន បណ្ណសារដ្ឋានជាតិ បណ្ណាល័យនានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

## ៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៥.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

-បានកសាងផែនការយុទ្ធសាស្ត្រ ៣ឆ្នាំរំកិល (ឆ្នាំ២០២៤-២០២៦) និងគម្រោងថវិកា ឆ្នាំ២០២៤ របស់ព្រឹទ្ធសភា

-បានរៀបចំរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភា ឆ្នាំ២០២២ និងការបែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភា ឆ្នាំ២០២៣ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-បានផ្ញើរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភា ប្រចាំឆមាសទី១ និងប្រចាំឆ្នាំ២០២៣ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-បានរៀបចំផែនការសកម្មភាពដំណាក់កាលទី៤ (MAP4) ឆ្នាំ២០២៣ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

-បានចូលរួមប្រជុំ សិក្ខាសាលា ពិគ្រោះយោបល់លើការងារពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ចំនួន ៣៨លើក

-បានធ្វើតារាងប្រាក់បៀវត្សប្រចាំឆ្នាំ២០២៣ ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានបើកប្រាក់បៀវត្សប្រចាំខែមករា ដល់ខែធ្នូ ឆ្នាំ២០២៣ ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការបុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងគោលការណ៍ថ្មីអំពីការផ្តល់របបផ្សេងៗតាមរយៈធនាគារ

-បានធ្វើលិខិតបុរេប្រទាន និងឥណទានបន្ថែមជំពូក៦១ សម្រាប់ចំណាយលើការទទួលដំណើរទស្សនកិច្ចផ្លូវការរបស់ប្រធានាធិបតី នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នៅព្រះរាជាណាចក្រកម្ពុជា និងចំណាយលើការសាងសង់របងថ្ម ជួសជុលកែលម្អសាលប្រជុំព្រឹទ្ធសភា និងការិយាល័យថ្នាក់ដឹកនាំព្រឹទ្ធសភាថ្មី

-បានធ្វើលិខិតសុំឥណទានបន្ថែម និងបុរេប្រទានថវិកា សម្រាប់ចំណាយសាងសង់ ជួសជុលហេដ្ឋារចនាសម្ព័ន្ធ អគារ ជណ្តើរយន្ត និងបំពាក់សម្ភារ បរិក្ខារ ក្នុងព្រឹទ្ធសភា គោរពជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានធ្វើលិខិតស្នើសុំឥណទានបន្ថែមសម្រាប់៖

- ដំឡើងថ្នាក់បៀវត្សមូលដ្ឋាន
- ចំណាយលើការដឹកនាំគណៈប្រតិភូព្រឹទ្ធសភាចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤២ នៅសាធារណរដ្ឋឥណ្ឌូនេស៊ី
- ចំណាយលើការទទួលគណៈប្រតិភូសាធារណរដ្ឋប្រជាមានិតចិន មកទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ចំនួន ០២លើក

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់បុរេប្រទានថវិកា ចំនួន ២,០៦៦,២៨០,០០០រៀល គឺស្មើនឹង ៤០% នៃទឹកប្រាក់ ចំនួន ៥,១៦៥,៧០០,០០០រៀល សម្រាប់សាងសង់ជណ្តើរយន្ត ចំនួន ០៤គ្រឿង ផ្លាស់ប្តូរម៉ាស៊ីនត្រជាក់ ទូរទឹកកក សង្ហារិម និងជួសជុលសាលប្រជុំពេញអង្គព្រឹទ្ធសភា

-បានរៀបចំកាត់ឯកសណ្ឋានសញ្ញាសក្តិជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានតាមដានគោលការណ៍ និងព័ត៌មានទាក់ទងនឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈ

-បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន ៦,០១១សំណើ

-បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា កម្មពិធីផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ១,០៩២សំណើ

-បានថតចម្លងឯកសារ ចំនួន ៤៨,៣៩៩ច្បាប់ និងចងក្រងធ្វើជាសៀវភៅ ចំនួន ៦៧១ក្បាល អស់ក្រដាសសរុបចំនួន ៦៧៧,៧០៧សន្លឹក

-បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន ២,៥៧៦លើក ស្មើនឹង ៦,៣០៦នាក់

-បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ បម្រើសេវាកេសដ្ឋៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន ៤២០លើក ស្មើនឹង ២៨,៦៥០នាក់

-បានទទួលលិខិតចូល ចំនួន ៨,៥៧៦ច្បាប់ និងបញ្ជូនលិខិតចេញ ចំនួន ៤,៣៨០ច្បាប់

-បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៥២០ច្បាប់ ស្មើនឹង ១,៥៥៦នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភា ចំនួន ៥៩ច្បាប់

-បានស្រង់ស្ថិតិមន្ត្រីរាជការដែលពិការភាពកំពុងបម្រើការងារក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគ ចំនួន ១,៥៣០លីត្រ ជូនអង្គភាពចំណុះអគ្គលេខាធិ-ការដ្ឋានព្រឹទ្ធសភា

-បានកែលម្អសោភ័ណភាព បរិស្ថាន ដើម្បីជួយរក្សាការពារបរិស្ថាន និងអនាម័យនៅក្នុងបរិវេណព្រឹទ្ធសភា ស្របតាមគោលការណ៍សភាបៃតង ដោយបំពាក់អំពូលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ កែលម្អសោភ័ណភាពសួនច្បារនានា និងដាំដើមឈើ និងផ្កាគ្រប់ប្រភេទសរុបចំនួន ៤,៣២០គុម្ព ព្រមទាំងបានថែសួន កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានាក្នុងបរិវេណព្រឹទ្ធសភា ចំនួន ៦១២លើក/ដើម

-បានទទួលលិខិតសុំអនុញ្ញាតច្បាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងកត់ត្រាចូលក្នុងសៀវភៅការងារ ចំនួន ៦៧១ច្បាប់

-បានធ្វើសេចក្ដីសម្រេចពាក់ព័ន្ធនឹងអត្ថប្រយោជន៍មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ១៥៣ច្បាប់

-បានធ្វើប័ណ្ណសម្គាល់ខ្លួន និងប័ណ្ណចេញ-ចូល ក្នុងបរិវេណព្រឹទ្ធសភា ចំនួន ២៤៧ប័ណ្ណ

-បានបោះពុម្ពសៀវភៅគោលការណ៍នានា ចំនួន ៣៥០ក្បាល, សៀវភៅការងារ ចំនួន ៣០០ក្បាល និងច្បាប់ស្ដីពី លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ចំនួន ២០០ក្បាល

-បានធ្វើជំរឿនមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឆ្នាំ២០២៣

-បានធ្វើជំរឿនសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋព្រឹទ្ធសភា និងធនធានមនុស្សនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឆ្នាំ២០២៣

-បានរៀបចំធ្វើសៀវភៅប្រវត្តិរូបសមាជិក សមាជិកាព្រឹទ្ធសភា នីតិកាលទី១ ដល់នីតិកាលទី៤

-បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានរៀបចំបែបបទប្រឡងប្ដូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ១០នាក់

-បានវាយតម្លៃសមត្ថភាពមន្ត្រីរាជការតែងតាំងមុខតំណែងគ្រប់គ្រងក្នុងអង្គការលេខនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ១៥៥នាក់ ដំឡើងឋានន្តរសក្តិប្រចាំឆ្នាំ ចំនួន ២៦៦នាក់ ដំឡើងថ្នាក់បៀវត្ស ចំនួន ២៦៦នាក់

-បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែមករា ដល់ខែធ្នូ ឆ្នាំ២០២៣ ចំនួន ៤៣នាក់

-បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មី

-បានទទួលអាហារូបករណ៍ក្នុងប្រទេស ពីសាកលវិទ្យាល័យ និងវិទ្យាស្ថាននានា ចំនួន ៩៨កន្លែង

-បានទទួលអាហារូករណ៍ក្រៅប្រទេស ពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA), ព្រះរាជាណាចក្រថៃឡង់ដ៍, សហរដ្ឋអាមេរិក, ប្រទេសអូស្ត្រាលី, សាធារណរដ្ឋឥណ្ឌា, ប្រទេសស្វីស និងសាធារណរដ្ឋសង្គមនិយមប្រជាធិបតេយ្យស្រីលង្កា និងបានបញ្ជូនមន្ត្រីរាជការទៅសិក្សា ចំនួន ១៣នាក់

-បានបណ្តុះបណ្តាលធនធានមនុស្សក្នុងប្រទេស រួមមាន៖

- បើកវគ្គបណ្តុះបណ្តាលក្នុងស្ថាប័ន ចំនួន ២៧វគ្គ មានសិក្ខាកាមចូលរួម ចំនួន ៨០០នាក់
- រៀបចំសិក្ខាសាលា កម្មវិធីធ្វើបាឋកថា ចំនួន ០៦លើក មានសិក្ខាកាមចូលរួម ចំនួន ៤៧១នាក់
- ចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានានៅក្រៅស្ថាប័ន ចំនួន ២១វគ្គ មានសិក្ខាកាមចូលរួម ចំនួន ១៥៩នាក់

-បានបណ្តុះបណ្តាលធនធានមនុស្សក្រៅប្រទេស រួមមាន៖

- ចូលរួមវគ្គបណ្តុះបណ្តាលនានា ចំនួន ២០វគ្គ មានសិក្ខាកាមចូលរួម ចំនួន ៣២នាក់
- ចូលរួមសិក្ខាសាលា ចំនួន ០៦លើក មានសិក្ខាកាមចូលរួម ចំនួន ១៩នាក់
- ចុះធ្វើកម្មសិក្សា និងទស្សនកិច្ចសិក្សា ចំនួន ០៣លើក មានសិក្ខាកាមចូលរួម ចំនួន ០៣នាក់

-បានចុះតាមដាន និងអង្កេតការណ៍ការធ្វើបទបង្ហាញតាមអង្គភាពនីមួយៗ ចំនួន ៥២លើក និងធ្វើរបាយការណ៍វាយតម្លៃមន្ត្រីដែលបានធ្វើបទបង្ហាញបន្ទាប់ពីបញ្ចប់វគ្គនីមួយៗ ចំនួន ១០៥នាក់

-បានធ្វើសម្រង់សារពើភណ្ឌជំនាញ និងតម្រូវការវគ្គបណ្តុះបណ្តាលឆ្នាំ២០២៤ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តធ្វើផែនការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សរយៈពេល ១០ឆ្នាំ (ឆ្នាំ២០២១-២០៣០) របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានបំពាក់សម្ភារ បរិក្ខារ និងមធ្យោបាយដែលចាំបាច់បំផុតជាជំហានៗ ជូនអង្គភាពស្នូលដែលត្រៀមរ៉ាប់រងការងារសំខាន់ៗនាពេលខាងមុខ

-បានរៀបចំសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសាលជំនួបធ្វើជាការិយាល័យថ្នាក់ដឹកនាំព្រឹទ្ធសភាថ្មី និងរៀបចំសាលសិក្ខាសាលាខាងត្បូងដើម្បីធ្វើជាសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសាលប្រជុំពេញអង្គព្រឹទ្ធសភាបណ្តោះអាសន្ន

-បានសាងសង់ ជួសជុល កែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗរួមមាន៖

- បានសាងសង់៖ របងថ្មីខាងមុខព្រឹទ្ធសភា ប្រវែង ១២០ម៉ែត្រ និងខ្លោងទ្វារ (ច្រកចេញ-ចូល P4), បំពាក់ជណ្តើរយន្តនៅអគារក្រហម ចំនួន ០៤គ្រឿង, រោងចំណតរថយន្ត ចំនួន ០៣កន្លែង, រោងដែកសម្រាប់អ្នកបើកបរ, ឃ្លាំងដាក់សម្ភារការិយាល័យ ចំនួន ០៣ឃ្លាំង និងធ្នើរដែកដាក់សៀវភៅនៅបណ្ណាល័យ, ប៉ុស្តិ៍យាម(P1) ព្រមទាំងបន្តកសាងខ្លោងទ្វារ (ច្រកចេញ-ចូល P3)
- បានជួសជុលកែលម្អ៖ អគារក្រហម និងផ្នែកខាងមុខអគារក្រហម, សាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ធ្វើជាសាលទទួលភ្ញៀវ, អគារថ្នាក់ដឹកនាំព្រឹទ្ធសភាទាំង៣, អគារឯកឧត្តមនាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា, សាលសិក្ខាសាលាខាងត្បូង, សាលសិក្ខាសាលាខាងជើង, អគារគណៈកម្មការព្រឹទ្ធសភា, មជ្ឈមណ្ឌលសភាអាស៊ី(PCAsia), នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ, នាយកដ្ឋានរដ្ឋបាល, នាយកដ្ឋានភូមិភាគ និងសមូហភាពដែនដី, នាយកដ្ឋានជំនួយការគណៈកម្មការ, អគារនៅទល់មុខអគារមូលនិធិខ្មែរអភិវឌ្ឍន៍, បន្ទប់ជំនួយការ-ទីប្រឹក្សាឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា, ការិយាល័យឯកឧត្តមអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ, កន្លែងតុងកាហ្វេនៅខាងមុខសាលពិសេស៣ និងសាលសិក្ខាសាលាខាងត្បូង, រោងម៉ាស៊ីនភ្លើងជាប់នាយកដ្ឋានរដ្ឋបាល
- បានជួសជុលកែលម្អ និងរៀបចំទីកន្លែងធ្វើការជូនឯកឧត្តមអគ្គលេខាធិការរងថ្មី, អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ, ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ
- បានខាត់ លាប និងប្តូរការ៉ូបាតថ្មីនៅបន្ទប់សមាជិកព្រឹទ្ធសភា និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ១៤បន្ទប់
- បានលាបថ្នាំ៖ អគារមូលនិធិខ្មែរអភិវឌ្ឍន៍, បន្ទប់អគ្គនាយកពិធីការ និងទំនាក់ទំនងអន្តរជាតិ និងបន្ទប់ជំនួយការតាមផ្លូវដើរជាន់ក្រោមអគារA, របងព្រឹទ្ធសភា, រូបសំណាកវិមានឯករាជ្យ, ដងទង់ជាតិ និងលាបគំនូសចរាចរណ៍នៅជុំវិញបណ្ណាល័យ
- បានបាំងបន្ទប់កញ្ចក់អាលុយមីញ៉ូមទូម៉ាស៊ីនRack នៅអគារជប៉ុនទី១ ទី២ និងអគារA.B.C
- បានរៀបថ្មម៉ាប តម្រង់ខឿនថ្មម៉ាប និងចាក់សាបស៊ីម៉ងត៍ ព្រមទាំងបូប ស្តារប្រព័ន្ធលូ និងជួសជុលគម្របលូ ក្នុងបរិវេណព្រឹទ្ធសភា
- បានផ្លាស់ប្តូរព្រំថ្មីនៅអគារក្រហម និងអគារ D E F

-បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី, ត្រួតពិនិត្យជណ្តើរយន្ត សត្វកណ្តៀរ, រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម, ប្រមូលសម្ភារខូច, បិទលេខកូដសម្ភារសារពើភណ្ឌ, ប្រគល់ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន ៣,៣៧៨គ្រឿង/លើក

-បានបំពាក់បំពង់ពន្លត់អគ្គិភ័យថ្មី និងជួសជុលបំពង់ពន្លត់អគ្គិភ័យចាស់ដែលខូចគុណភាព ចំនួន ៦៣គ្រឿង/បំពង់

-បានប្រចាំការត្រួតពិនិត្យម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ និងការប្រើប្រាស់ទឹក ភ្លើងក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាក ចំនួន ៣៧៨លើក

-បានរៀបចំរបាយការណ៍ស្តីពី ការកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋនៃព្រឹទ្ធសភា ប្រគល់ជូនអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានធ្វើរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចន្លោះសម័យប្រជុំលើកទី៩ និងលើកទី១០, លើកទី១០ និងលើកទី១១ នីតិកាលទី៤ ចំនួន ០២លើក

-បានបូកសរុបលទ្ធផលការងារព្រឹទ្ធសភា នីតិកាលទី៤ (២០១៨-២០២៤)

-បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែមករា ដល់ខែធ្នូ, ប្រចាំឆមាសទី១, ប្រចាំនព្វមាស និងប្រចាំឆ្នាំ២០២៣ ទូលថ្វាយព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

-បានធ្វើបទបង្ហាញស្តីពី លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា ដល់ខែធ្នូ, ប្រចាំត្រីមាសទី១, ប្រចាំឆមាសទី១, ប្រចាំនព្វមាស និងប្រចាំឆ្នាំ២០២៣ ព្រមទាំងលើកទិសដៅការងារឆ្នាំ២០២៤

-បានធ្វើសម្រង់ស្ថិតិ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា ដល់ខែធ្នូ, ប្រចាំឆមាសទី១, ប្រចាំនព្វមាស និងប្រចាំឆ្នាំ២០២៣ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា

-បានធ្វើរបាយការណ៍ស្តីពី ការពិនិត្យ និងតាមដានការអនុវត្តផែនការប្រតិបត្តិរបស់នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានទាំង៩ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំត្រីមាសទី១, ទី២, ទី៣ និងទី៤ ឆ្នាំ២០២៣ ចំនួន ០៤លើក

-បានធ្វើបញ្ជីសម្រង់ស្ថិតិមន្ត្រីរាជការ និងបុគ្គលិក ដែលស្នាក់នៅជាអចិន្ត្រៃយ៍ និងសម្រាកថ្ងៃត្រង់ ព្រមទាំងយានយន្តរបស់មន្ត្រីរាជការ និងបុគ្គលិក ដែលចេញ-ចូលក្នុងបរិវេណព្រឹទ្ធសភា

-បានត្រួតពិនិត្យតាមកាមេរ៉ាសុវត្ថិភាពរាល់ថ្ងៃ ព្រមទាំងជួសជុល ប្តូរ និងថែទាំកាមេរ៉ាសុវត្ថិភាពជាប្រចាំ

-បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ចំនួន ១៧៤លើក។

**៤.២-ការងារសេវាច្បាប់៖**

-បានទទួលសេចក្តីព្រាងច្បាប់ ចំនួន ២៣ច្បាប់ ពីទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋសភា

-បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរណែនាំ របាយ-ការណ៍ សេចក្តីជូនដំណឹង និងលិខិតផ្សេងៗ ចំនួន ៤,០៣៩ច្បាប់

-បានធ្វើកំណត់បង្ហាញរបាយការណ៍សវនកម្ម ចំនួន ៧៥ច្បាប់

-បានតាមដានដំណើរការវិវឌ្ឍន៍សម័យប្រជុំរបស់រដ្ឋសភា

-បានធ្វើកំណត់ហេតុពិស្តារ និងកំណត់ហេតុសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រជុំពេញអង្គព្រឹទ្ធសភា និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន ៦០លើក

-បានប្រមូលផ្តុំចងក្រងឯកសារ លិខិតបទដ្ឋាននានា និងបោះពុម្ពសៀវភៅស្តីពី៖

- កម្រងកំណត់ហេតុសង្ខេប និងកម្រងកំណត់ហេតុពិស្តារ នៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤
- សម្រង់លទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៤ (ឆ្នាំ២០១៨-២០២៤)
- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា (បច្ចុប្បន្នភាព ខែកញ្ញា ឆ្នាំ២០២២)
- បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា (បច្ចុប្បន្នភាព ខែមីនា ឆ្នាំ២០២៣)
- ច្បាប់ស្តីពី លក្ខន្តិកៈសមាជិកព្រឹទ្ធសភា ជាបីភាសា (ភាសាខ្មែរ អង់គ្លេស និងភាសាបារាំង)
- ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ភូមិភាគទាំង៨
- កម្រងឯកសារស្តីពី កិច្ចប្រជុំបូកសរុបលទ្ធផលការអនុវត្តមុខងារតំណាងឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភា
- កម្រងសៀវភៅណែនាំស្តីពី បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាល
- សមិទ្ធផលការងារព្រឹទ្ធសភា នីតិកាលទី៤ (ឆ្នាំ២០១៨-២០២៤)

-បានចងក្រងទិន្នន័យក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ និងតំណាងរាស្ត្រ ដែលជាអង្គបោះឆ្នោតរបស់ព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤

-បានចងក្រងសេចក្ដីព្រាងឯកសារគោលសំខាន់ៗសម្រាប់ព្រឹទ្ធសភា នីតិកាលទី៥ ដើម្បីរួមចំណែកអភិវឌ្ឍន៍ឃុំ-សង្កាត់

-បានធ្វើបច្ចុប្បន្នភាពប្រតិទិនសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៤

-បានធ្វើបច្ចុប្បន្នភាព និងចងក្រងបញ្ជីសេចក្ដីព្រាងច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ តាមឆ្នាំ និងនីតិកាលនីមួយៗ

-បានបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ទីប្រឹក្សាជំនួយការថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីលេខាធិការដ្ឋានតាមរបប ០២ឆ្នាំ ចប់អាណត្តិ និងទទួលតំណែងថ្មី ឆ្នាំ២០២៣ នៅព្រឹទ្ធសភា ទៅអង្គភាពប្រឆាំងអំពើពុករលួយ និងផ្ទៀងផ្ទាត់ឈ្មោះស្ទួននៅសាមីក្រសួងស្ថាប័នផ្សេងៗ ចំនួន ១៩៨នាក់

-បានផលិតខ្សែវីដេអូស្ដីពី កិច្ចសម្ភាសន៍រវាងអ្នកនាំពាក្យព្រឹទ្ធសភា ជាមួយអ្នកសារព័ត៌មានអន្តរជាតិ ដើម្បីផ្សព្វផ្សាយក្នុងបណ្ដាញសង្គម ចំនួន ១២លើក

-បានប្រមូលចងក្រង និងសង្ខេបព័ត៌មានជាតិ-អន្តរជាតិ ព្រមទាំងបកប្រែព័ត៌មានអន្តរជាតិសំខាន់ៗ ចំនួន ២១,៦២១អត្ថបទ ជូនអ្នកនាំពាក្យព្រឹទ្ធសភា។

**៥.៣-ការងារស្រាវជ្រាវ៖**

-បានសិក្សា ស្រាវជ្រាវ និងផលិតឯកសារជំនួយស្មារតីលើសេចក្ដីព្រាងច្បាប់ ចំនួន ២៣ច្បាប់

-បានសិក្សា ស្រាវជ្រាវ ប្រមូលព័ត៌មាន និងផលិតអត្ថបទដោយផ្ដោតទៅលើទិដ្ឋភាពគតិយុត្ត យន្តការ វិធានការ បទពិសោធន៍នៃការអនុវត្ត ចំនួន ២៤អត្ថបទ

-បានតាមដាន និងសិក្សាស្រាវជ្រាវការអនុវត្តការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ

-បានតាមដានព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានតាមដាន និងចងក្រងឯកសារវាយតម្លៃពាក់កណ្ដាលអាណត្តិនៃការអនុវត្តគោលនយោបាយឧស្សាហកម្ម (ឆ្នាំ២០១៥-២០២៥) ចំនួន ០៣អត្ថបទ

-បានសិក្សាស្រាវជ្រាវ និងធ្វើសំយោគឯកសារព័ត៌មាន និងសង្ខេបខ្លឹមសារពាក់ព័ន្ធនឹងវិស័យនានា ចំនួន ៨៨៣ច្បាប់

-បានចងក្រងគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម (ឆ្នាំ២០២២-២០២៦) ចំនួន ០៥អត្ថបទ

-បានសិក្សាស្រាវជ្រាវ និងផលិតឯកសារផ្សេងៗពាក់ព័ន្ធនឹងច្បាប់ សេដ្ឋកិច្ច សង្គម ថវិកា សម្រេចបាន ចំនួន ២៣ប្រធានបទ

-បានរៀបចំប្រព័ន្ធទិន្នន័យថវិកា (Budget Database System) ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (ឆ្នាំ២០១៥-២០២៣)

-បានបំប្លែងឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តតាមវិស័យទៅជាឯកសារឌីជីថល និងធ្វើបច្ចុប្បន្នភាពកម្រងច្បាប់ព្រឹទ្ធសភាក្នុងប្រព័ន្ធមូលទិន្នន័យ៖

- ប្រមូល និងរៀបចំចងក្រងរាជកិច្ច (លេខ១ ដល់លេខ១៥ ឆ្នាំ២០១៨), (លេខ៥៨ ដល់លេខ៨២ ឆ្នាំ២០២១), (លេខ២១ ដល់៧៨ ឆ្នាំ២០២២)
- ផលិតទិន្នន័យតាមវិស័យរបស់គណៈកម្មការជំនាញទាំង១០ ចំនួន ២៩០ទិន្នន័យ

-បានចងក្រងព័ត៌មានសភាអន្តរជាតិប្រចាំសប្តាហ៍ ចំនួន ៤៨ច្បាប់

-បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិ ចំនួន ៩៥៥អត្ថបទ

-បានផលិតព្រឹត្តិបត្រស្រាវជ្រាវតាមវិស័យប្រចាំសប្តាហ៍ (Weekly E-Bulletin) ចំនួន ៤៣ច្បាប់ និងព្រឹត្តិបត្រព័ត៌មានសង្ខេប (Briefing Fact Sheet) ចំនួន ២០ច្បាប់

-បានផលិតព្រឹត្តិបត្រព័ត៌មានសេដ្ឋកិច្ច-សង្គម (Research Journal) ចេញផ្សាយប្រចាំខែ ចំនួន ១២ច្បាប់

-បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែមករា ដល់ខែធ្នូ ឆ្នាំ២០២៣ ចំនួន ៤៨ច្បាប់។

**៥.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

-បានបំពាក់ឧបករណ៍បច្ចេកទេស ចំនួន ១៨៧គ្រឿង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបណ្តាញមេ (Core System) និងរៀបចំប្រព័ន្ធការពារ (Firewall)ថ្មីក្នុងបន្ទប់ទិន្នន័យ ដើម្បីគ្រប់គ្រង ចែកចាយការប្រើប្រាស់សេវាអ៊ីនធឺណែតក្នុងព្រឹទ្ធសភាឱ្យដំណើរការសមស្រប និងមានល្បឿនលឿនសម្រាប់គ្រប់អង្គភាពប្រើប្រាស់បំពេញការងារ

-បានរៀបចំកម្មវិធីទូរស័ព្ទ (Mobile Application) សម្រាប់គាំទ្រទៅលើការផ្សព្វផ្សាយពីដំណើរការ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងសាធារណជន

-បានរៀបចំកម្មវិធីទទួលពាក្យបណ្តឹងព្រឹទ្ធសភាអេឡិចត្រូនិច (Mobile Application) និងយុទ្ធសាស្ត្រផ្សព្វផ្សាយ

-បានសិក្សា និងរៀបចំប្រព័ន្ធបណ្ណសារអេឡិចត្រូនិច (E-archive )ដែលមានលក្ខណៈស្តង់ដារសម្រាប់បណ្ណសារដ្ឋាន និងបណ្ណាល័យព្រឹទ្ធសភា

-បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ពង្រឹងពង្រីកការផ្គត់ផ្គង់ និងជួសជុលឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេក-វិទ្យាព័ត៌មាន ចំនួន ១,១១០គ្រឿង/លើក

-បានទទួលឯកសារ ទស្សនាវដ្តី ព្រឹត្តិបត្រ រាជកិច្ច សៀវភៅច្បាប់ និងសៀវភៅជំនាញផ្សេងៗ ចំនួន ២,៣៥៣ក្បាល ព្រមទាំងបានបោះត្រាសៀវភៅ ដាក់លេខកូដសៀវភៅ ចុះបញ្ជីសៀវភៅ អ៊ុតក្រប សៀវភៅ បិទប័ណ្ណខ្នី និងសងសៀវភៅ ចំនួន ២,៩០៥ក្បាល

-បានរៀបចំបញ្ចូលទិន្នន័យឯកសារ និងសៀវភៅអង់គ្លេសក្នុងកម្មវិធីកូហា ចំនួន ២,២៣៨ក្បាល

-បានរៀបចំបញ្ចូលឯកសារ សៀវភៅច្បាប់ សៀវភៅបោះពុម្ពដោយព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងសៀវភៅផ្សេងៗតាម https: ebook.senate-elibrary.com ចំនួន ៨០៨ក្បាល

-បានបង្កើតផេក TikTok ជាផ្លូវការរបស់បណ្ណាល័យព្រឹទ្ធសភា ព្រមទាំងបានផ្សព្វផ្សាយឯកសារ និងសៀវភៅដែលមាននៅក្នុងបណ្ណាល័យព្រឹទ្ធសភា (ក្នុងនោះមានអ្នក Follower ចំនួន ១,១២១នាក់ និងអ្នក Like ចំនួន ១៥,៦០០នាក់)

-បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងារព្រឹទ្ធសភា ចំនួន ១២០លើក

-បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងារព្រឹទ្ធសភា តាមប្រព័ន្ធFacebook, Instagram, Twitter, Youtube និងTiktok ចំនួន ៥,៨៣៣លើក

-បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងារព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន ១,៥៥៣ប្រធានបទ

-បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុង Channel Telegram ព័ត៌មានប្រចាំថ្ងៃ ចំនួន ៣២,៣៦៨ ប្រធានបទ

-បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃ ចំនួន ៥២៣លើក និងទស្សនព័ត៌មានប្រចាំថ្ងៃ ចំនួន ២២៧លើក

-បានរៀបចំផលិត Poster បុណ្យជាតិ ចំនួន ១០លើក

-បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ ក្រុមភូមិភាគទាំង៨ ក្រុមយន្តការនានារបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅខ្លោងទ្វារធំព្រឹទ្ធសភា និងខាងមុខអគារក្រហមព្រឹទ្ធសភា ព្រមទាំងពិធីផ្សេងៗ ចំនួន ១៣១លើក

-បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន សភាបៃតង សភាឌីជីថល រដ្ឋបាលអេឡិចត្រូនិច ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភា និងពិធីផ្សេងៗឱ្យបានលឿន ល្អ និងរលូនៗ

**៤.៥-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖**

-បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន ២៣២លើក

-បានរៀបចំ និងបញ្ជូនសារលិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ និងរំលែកទុក្ខរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនឥស្សរជនជាន់ខ្ពស់នៃបណ្ដាប្រទេសជាមិត្ត ថ្នាក់ដឹកនាំអង្គការអន្តរសភា និងស្ថានទូតប្រចាំព្រះរាជាណាចក្រកម្ពុជា ចំនួន ៣៥២លើក

-បានកសាងជំនួយស្មារតី សុន្ទរកថា បទអន្តរាគមន៍ និងបកប្រែឯកសារនានា ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន ១១១ច្បាប់/លើក

-បានតាមដាន និងចងក្រងសេចក្ដីប្រកាសព័ត៌មាន និងសេចក្ដីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន ៩៤ច្បាប់

-បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែមករា ដល់ខែវិច្ឆិកា និងប្រចាំឆ្នាំ២០២៣ ចំនួន ១២ច្បាប់

-បានចងក្រងធ្វើសៀវភៅ ស្ដីពី (APPF-30), (AIPA-43) និង(IPU-147) ចំនួន ០៣លើក

-បានចងក្រងសៀវភៅស្ដីពី លទ្ធផលនៃមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៤ (AIPA-44) ចំនួន ០៣លើក

-បានចងក្រងឯកសារ បញ្ជីឈ្មោះអង្គការជាតិ និងអង្គការអន្តរជាតិ សេចក្ដីប្រកាសព័ត៌មាន និងសេចក្ដីថ្លែងការណ៍រួមរបស់អង្គការសង្គមស៊ីវិល និងក្រសួងនានា

-បានតុបតែងលម្អ បំភ្លឺភ្លើងពណ៌ ដាក់តាំងព្រះឆាយាល័ក្ខណ៍អមដោយហ្វូងអក្សរ និងចងបដាពាក្យស្លោក ក្នុងឱកាសនៃពិធីបុណ្យផ្សេងៗ ចំនួន ១០លើក

-បានស្នើសុំលិខិតឆ្លងដែនផ្លូវការថ្មីជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ២៩ច្បាប់។

**៤.៦-ការងារអគ្គាធិការដ្ឋាន៖**

-បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆ្នាំ២០២៣ ចំនួន ២២៨លើក

-បានប្រជុំពិភាក្សាការងារជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ០៤លើក ព្រមទាំងបានធ្វើរបាយការណ៍ស្ដីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គលេខា-ការដ្ឋានព្រឹទ្ធសភា

-បានចុះត្រួតពិនិត្យជាក់ស្តែងតាមនាយកដ្ឋាន ចំនួន ២៤លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមានដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកនាយកដ្ឋានគ្រប់គ្រងផ្ទៃក្នុងនៃអគ្គាធិការដ្ឋានរៀងរាល់ថ្ងៃ និងរបាយការណ៍ជូនថ្នាក់ដឹកនាំ

-បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃ ចំនួន ៤៦២លើក ប្រចាំសប្តាហ៍ ចំនួន ៤៨លើក និងប្រចាំខែមករា ដល់ខែធ្នូ ឆ្នាំ២០២៣

-បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា

-បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំឆ្នាំ២០២៣ ចំនួន ១៦លើក។

**៤.៧-ការងារសង្គមកិច្ចៈ**

-គណៈកម្មការមូលដ្ឋានអគ្គលេខាធិការដ្ឋានព្រឹទ្ធសភានៃសមាគមសង្គហៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ បានឧបត្ថម្ភដល់មន្ត្រីរាជការ និវត្តជន និងសហព័ទ្ធ ដែលបានទទួលមរណភាព ចំនួន ០៧នាក់ សរុបថវិកា ចំនួន ២៥,៦០០,០០០រៀល ដើម្បីជួយសម្រាលទុក្ខលំបាកដល់ក្រុមគ្រួសារសព

-អង្គភាពមូលនិធិសង្គមកិច្ច បានជួយឧបត្ថម្ភថវិកាដល់មន្ត្រីរាជការ និងសហព័ទ្ធ ចំនួន ១៤២សំណើ ដើម្បីពិនិត្យ ព្យាបាលជំងឺ និងទទួលមរណភាពសរុបចំនួន ៣៣១,៦៦៨,៨០០រៀល

-បានរៀបចំទិវាអន្តរជាតិនារី ០៨មីនា និងទិវាមនុស្សចាស់ ចំនួន ០២លើក ព្រមទាំងបានឧបត្ថម្ភថវិកាដល់មន្ត្រីរាជការជាស្ត្រី មន្ត្រីរាជការវ័យចំណាស់ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានចុះសួរសុខទុក្ខសមាជិក សមាជិកាព្រឹទ្ធសភា និងនិវត្តជន មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានជំងឺ ជួបគ្រោះថ្នាក់ចរាចរណ៍ លំហែមាតុភាព ចំនួន ៧៥នាក់

-បាននាំយកថវិការបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឧបត្ថម្ភជូនមន្ទីរពេទ្យគន្ធបុប្ផាកម្ពុជា ប្រចាំឆ្នាំ២០២៣ ចំនួន ៥៦,៤២០,០០០រៀល

-បានរៀបចំទេយ្យទាន និងគ្រឿងសក្ការបូជាសម្រាប់រាប់បាត្រប្រគេនព្រះសង្ឃ ក្នុងពិធីបុណ្យមាឃបូជា និងវិសាខបូជា ចំនួន ០២លើក (ចំនួន ១៦០កញ្ចប់) ព្រមទាំងរៀបចំអំណោយជូនគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ ចំនួន ០២លើក (ចំនួន ៦០កញ្ចប់)

-បានរៀបចំបន្ទប់ពេទ្យប្រចាំការជាអចិន្ត្រៃយ៍សម្រាប់សង្គ្រោះបឋមនៅក្នុងបរិវេណព្រឹទ្ធសភា និងបានធ្វើប័ណ្ណសមាជិកបេឡាជាតិសន្តិសុខសង្គម ចំនួន ៨៩ប័ណ្ណ ដោយអនុវត្តនូវផ្នែកថែទាំសុខភាព និងហានិភ័យការងារ

-បានសហការ និងសម្របសម្រួលជាមួយក្រុមគ្រូពេទ្យមកពីមន្ទីរពេទ្យកាល់ម៉ែតចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី៦ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា, ថ្នាក់ដឹកនាំ សមាជិក សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ,ទីប្រឹក្សារបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា, ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា រួមទាំងក្រុមគ្រួសារ សរុបចំនួន ១,០២៥នាក់

-បានសម្របសម្រួលក្នុងកម្មវិធីពិនិត្យភ្នែក និងវាស់កាត់វ៉ែនតា ដោយឥតគិតថ្លៃ ជូនសមាជិកព្រឹទ្ធសភា ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៧៤១នាក់។

**II-ទិសដៅការងារឆ្នាំ២០២៤**

ស្ថិតក្នុងអន្តរកាលឆ្ពោះទៅការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤, ការបញ្ចប់នីតិកាលទី៤ និងការចាប់ផ្តើមនីតិកាលទី៥ ដោយរលូន ហើយជានាប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។

**១- មុខងារនីតិកម្ម**

-ត្រៀមរៀបចំពិធីបើកសម័យប្រជុំដំបូង នីតិកាលទី៥ ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ។

**២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖

- អញ្ជើញចុះជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន និងអាជ្ញាធរដែនដី ដើម្បីដោះស្រាយទុក្ខលំបាក បញ្ហាប្រឈម សំណូមពរនានា ជំរុញការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងគោលនយោបាយនានា ព្រមទាំងចូលរួមពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា
- អញ្ជើញចូលរួមកិច្ចប្រជុំ វេទិកា សិក្ខាសាលា ពិធីបុណ្យជាតិ-អន្តរជាតិ និងពិធីសាសនា

-ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជនមកកាន់ព្រឹទ្ធសភា

-ត្រៀមទទួលពាក្យបណ្តឹង និងសហការជាមួយក្រសួង ស្ថាប័ន មានសមត្ថកិច្ច ដើម្បីដោះស្រាយបណ្តឹងជូនប្រជាពលរដ្ឋ។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ក្នុងពិធីជំនួបជាមួយឥស្សរជនជាន់ខ្ពស់បរទេស និងអង្គទូតនានានៃប្រទេសជាមិត្ត

-ត្រៀមចូលរួមកម្មវិធីការទូតសភាតំបន់ និងអន្តរជាតិ តាមរយៈការចូលរួមមហាសន្និបាត កិច្ចប្រជុំ សិក្ខាសាលា វេទិកា កម្មវិធីជំនួប និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ ដើម្បីលើកកម្ពស់កិត្យានុភាពជាតិលើអន្តរជាតិ ជំរុញការអភិវឌ្ឍសង្គមសេដ្ឋកិច្ច វប្បធម៌ ទេសចរណ៍ និងពាណិជ្ជកម្ម

-ត្រៀមទទួលបដិសណ្ឋារកិច្ចគណៈប្រតិភូជាន់ខ្ពស់នានា អញ្ជើញមកបំពេញទស្សនកិច្ចនៅព្រឹទ្ធសភា

-ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU)ជាមួយដៃគូអភិវឌ្ឍន៍

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

-សហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន

-លើកកម្ពស់ការងារស្រាវជ្រាវ បកប្រែ និងផលិតឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បំពេញមុខងារស្នូលទាំង៣ៈ មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ មុខងារតំណាង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

-ត្រៀមធ្វើសារលិខិតជូនពរ និងសារលិខិតអបអរសាទររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជូនថ្នាក់ដឹកនាំ និងឥស្សរជនជាន់ខ្ពស់នៃបណ្តាប្រទេសជាមិត្ត

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមពិធីបុណ្យជាតិរបស់បណ្តាប្រទេសជាមិត្តៗ

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-ត្រៀមរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភាប្រចាំឆ្នាំ២០២៣ និងការបែងចែកឥណទានឆ្នាំ២០២៤ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-ត្រៀមកសាង និងការពារគម្រោងថវិកាឆ្នាំ២០២៥ ក្នុងកម្រិតរដ្ឋបាល និងនយោបាយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ការដំឡើងប្រាក់បំណាច់មុខងារដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសម្រាប់ឆ្នាំ២០២៤

-ត្រៀមរៀបចំបែបបទដំឡើងមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆ្នាំ២០២៤ ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋព្រឹទ្ធសភា និងសារពើភណ្ឌធនធានមនុស្ស

-ត្រៀមរៀបចំគោលការណ៍ គោលនយោបាយថ្មីៗ ស្របតាមដំណើរការងារ និងការវិវដ្តថ្មីៗ

-ត្រៀមអនុវត្តផែនការបណ្តុះបណ្តាលសម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឆ្នាំ២០២៤

-បន្តបច្ចុប្បន្នភាពផែនការការងារសម្រាប់ការត្រៀមទទួលនីតិកាលទី៥របស់ព្រឹទ្ធសភា និងការខិតខំបញ្ចប់ការជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារការិយាល័យធ្វើការ រួមទាំងការបំពាក់សម្ភារឧបករណ៍ថ្មី និងការត្រៀមលក្ខណៈសម្បត្តិជាមុន ការបើកសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៥

-បន្តតាមដានជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថានទូតចិន ស្ថានទូតវៀតណាម ទីប្រឹក្សាសេដ្ឋកិច្ច និងពាណិជ្ជកម្មចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា លើគម្រោងស្នើកសាងអគារថ្មី១ខ្នង និងការស្វែងរកជំនួយពីរដ្ឋាភិបាលនៃប្រទេសជាមិត្តសម្រាប់នីតិកាលថ្មីខាងមុខ

-លើកកម្ពស់សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង សម្ភារ និងបច្ចេកវិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

-ត្រៀមរៀបចំផលិតខ្សែវីដេអូព័ត៌មានរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

**III-សេចក្តីសន្និដ្ឋាន**

ក្នុងឆ្នាំ២០២៣នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានអនុវត្តការងារសម្រេចបានលទ្ធផលល្អប្រសើរជាងឆ្នាំ២០២២។ លទ្ធផលទាំងនេះជាសូចនាករនៃការដឹកនាំ គ្រប់គ្រង និងការខិតខំប្រឹងប្រែងដោយស្មារតីទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ។

ដើម្បីឱ្យការអនុវត្តផែនការប្រតិបត្តិឆ្នាំ២០២៤ សម្រេចបានលទ្ធផលច្រើនជាងឆ្នាំ២០២៣ គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពទាំងអស់បន្តយកចិត្តទុកដាក់បំពេញការងារប្រកបដោយឆន្ទៈ មនសិការ បុរេសកម្ម សកម្ម អន្តរសកម្ម ប្រសិទ្ធភាព និងប្រសិទ្ធផល ឆ្លើយតបបានទៅនឹងតម្រូវការរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងសម្រេចបានបេសកកម្មរបស់ស្ថាប័ន។

ឯកភាព សាមគ្គីភាព និងសហប្រតិបត្តិការគ្នាដ៏ល្អប្រពៃ គឺជាមូលដ្ឋានគ្រឹះនៃដំណើរឈានទៅមុខប្រកបដោយជោគជ័យរបស់ស្ថាប័នព្រឹទ្ធសភាយើង។

ការងារបញ្ចប់នីតិកាលទី៤ និងការងារផ្តើមនីតិកាលទី៥ ឱ្យបានល្អប្រសើរ គឺជាកាតព្វកិច្ចចាំបាច់បំផុតដែលត្រូវប្រមូលផ្តុំការខិតខំឱ្យសម្រេចបានទាន់ពេលវេលា គ្រប់មុខសញ្ញា និងគ្រប់វិស័យ។

ថ្ងៃចន្ទ ១២រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤

**អគ្គលេខាធិការ**

**អ៊ុំ សារឹទ្ធ**